ជម្រើសសការងារ

ប្រសិនបើអតិថិជនទទួលសេវាការងារសម្រាប់យ៉ាងតិចប្រាំបួនខែ ពួកគេអាចជ្រើសសេវាបញ្ជូនសហគមន៍។

ការបញ្ជូនសហគមន៍ភ្ជាប់ជនមានពិការភាពទៅនឹងមនុស្សក្នុងសហគមន៍។ នេះអនុញ្ញាតឲ្យពួកគេកសាងទំនាក់ទំនងជាមួយអ្នកដទៃដែលចែករំលែកចំណាប់អារម្មណ៍ស្រដៀងគ្នា។ សេវាគាំទ្រគឺត្រូវបានតម្រូវតាមបុគ្គល និងអាចជួយបុគ្គលនោះចូលរួមសមាគមន៍ ចូលរួមអង្គភាព និងក្វាយជាសមាជិកក្លឹប។ សម្រាប់ព័ត៌មានបន្ថែមចូលទៅ www.dshs.wa.gov/dda/county-best-practices។

ប្រធានធនធាសំណុំរឿង DDA អាចជួយជាមួយសំណើសម្រាប់ការលើកលែងដល់ទៅ ១ម្នាប់ប្រាំបួនខែ។



Region 1 North
Spokane
1-800-462-0624

Region 1 South
Yakima
1-800-822-7840

Region 2 North
Everett
1-800-788-2053

Region 2 South
Seattle
1-800-314-3296

Region 3 North
Tacoma
1-800-248-0949

Region 3 South
Tumwater
1-800-339-8227

Washington State Department of Social & Health Services
Transforming lives

DSHS 22-1463 CA (Rev. 9/19) Cambodian

សេវាគាំទ្រការងារ

សម្រាប់មនុស្សពេញវ័យ មានពិការភាព ខាងការលូតលាស់

Washington State Department of Social & Health Services
Transforming lives

រដ្ឋបាលពិការភាពខាងការលូតលាស់

នាយកដ្ឋានសង្គម និងសេវាមនុស្ស (DSHS)
រដ្ឋបាលពិការភាពខាងការលូតលាស់ (DDA)

ផ្តល់ការគាំទ្រការងារទៅកាន់មនុស្សពេញវ័យ។ ការមានសិទ្ធិគឺត្រូវកំណត់ដោយការវាយតម្លៃ DDA របស់បុគ្គល។ អតិថិជន DDA អាចស្វែងរកភ្នាក់ងារការងារដែលមានលក្ខណៈសម្បត្តិគ្រប់គ្រាន់គឺអាចរកបាន និងសេវាអ្វីដែលបានផ្តល់តាមរយៈប្រធានធនធានសំណុំរឿង។ ភាពសមល្អគឺសំខាន់ចំពោះភាពដោតជ័យ។ អតិថិជនត្រូវបានលើកទឹកចិត្តឱ្យសម្គាសន៍ទីភ្នាក់ងារអាចរកបាន និងជ្រើសមួយដែលផ្តល់ការគាំទ្រដែលត្រូវការ។

ផ្លូវទៅរកការងារ

ក្រោមគោលការណ៍រដ្ឋវ៉ាស៊ីនតោន បុគ្គលធ្វើការអាយុពី 21 ដល់ 61 ឆ្នាំ ត្រូវបានស្គាល់ថាជាសមាជិកមានតម្លៃនៃសហគមន៍ដែលស័ក្តិសមត្រូវបានផ្តល់ការងារយ៉ាងល្អសម្រាប់ការរៀងរៀន។ ផ្លូវទៅរកការងារគឺជា ផ្លូវតែមួយរបស់អតិថិជនដើម្បីស្វែងរកការងារ។ វាចាប់ផ្តើមជាមួយគម្រោងដែលពិចារណាគោលដៅអាជីព សេចក្តីត្រូវការ និងវិធីល្អបំផុតដើម្បីទទួលការគាំទ្រដែលត្រូវការ។

ផ្លូវទៅរកការងារ អាចរួមបញ្ចូល ៖

ការទទួល

ប្រជុំជំហ៊ានដើម្បីប្រមូល និងចែករំលែកព័ត៌មានមូលដ្ឋាន។

ស្វែងយល់

ទ្រឹស្តីផ្តោតលើមនុស្សចំពោះការសិក្សាពីការចូលចិត្ត និងការមិនចូលចិត្តរបស់អតិថិជន ចំណូលចិត្តការងារ គោលចំណង និងជំនាញ។

ការរៀបចំការងារ

សកម្មភាពត្រៀមខ្លួនធ្វើការងារ ដូចជាបទពិសោធន៍ការងារសាកល្បង ការគាំទ្ររួមក្ស្ត្រគ្រប់ចិត្តរយៈពេលខ្លី និងបណ្តុះបណ្តាលការដឹកជញ្ជូន។

ការធ្វើទីផ្សារ

ការកំណត់អត្តសញ្ញាណ និងការចរចារការងារ ការកសាងទំនាក់ទំនងជាមួយនិយោជក និងការអភិវឌ្ឍការងារ។

ការបង្វឹកការងារ

ការគាំទ្រដែលត្រូវការដើម្បីអនុវត្ត និងពូកែនៅកន្លែងធើការ។

ការរក្សាការងារ

គាំទ្រដើម្បីរក្សាការងារ ថែរក្សាទំនាក់ទំនងជាវិជ្ជមានជាមួយនិយោជក កំណត់ឱកាសចរចាបង្កើនការចំណាយ លើកកម្ពស់ និង/ឬអត្ថប្រយោជន៍ដែលបានបង្កើន។

ប្រភេទសេវាគាំទ្រការងារ

ការងារដែលគាំទ្របុគ្គល

ជួយអ្នកស្វែងរកការងារទទួល និងរក្សាការងារនៅ ឬប្រាក់ឈ្នួលអប្បរមា។ គាំទ្រឱកាសការងារ និងការអភិវឌ្ឍអាជីពគឺផ្អែកលើតម្រូវការបុគ្គល ចំណាប់អារម្មណ៍ និងសមត្ថភាព។

ការងារដែលគាំទ្រក្រុម

ផ្តល់ការត្រួតពិនិត្យកំពុងបន្ត និងការគាំទ្រដែលបានចែករំលែកសម្រាប់ពីរដល់ប្រាំបីជាជនមានពិការភាពក្នុងការកំណត់សហគមន៍។ ការគាំទ្រគឺត្រូវបានបម្រុងទុកដើម្បីទាំងឱ្យមានការងារបុគ្គល។ ឧទាហរណ៍ រួមទាំងយុតសម័យ ទេសភាព ឬក្រុមផ្សេងទៀត។

សម្រាប់ព័ត៌មានបន្ថែមលើអ្នកផ្តល់ការងារក្នុងតំបន់ ពិនិត្យគេហទំព័រស្វែងរកអ្នកផ្តល់នៅ ៖
www.statedata.info/washington/search

គេហទំព័រមានព័ត៌មានអំពី ៖

- អ្វីដែលអ្នកផ្តល់សេវាមានលទ្ធផលល្អបំផុត
- អ្វីត្រូវសួរនៅពេលជ្រើសអ្នកផ្តល់សេវា
- អ្វីធ្វើឱ្យអ្នកផ្តល់សេវាមានគុណភាពល្អ

ការកំណត់ម៉ោងគាំទ្រ

ចំនួនគាំទ្រម៉ោងដែលបានផ្តល់គឺបានកំណត់ដោយកម្រិតគាំទ្រ និងប្រវត្តិប្រាក់ឈ្នួល។

កម្រិតគាំទ្រធ្លាក់ក្រោមប្រភេទចំនួនខាងក្រោម ៖

1. ភាពប្រសប់ទាបសំដៅលើនរណាម្នាក់ដែលឯកសារផ្សក្នុងសហគមន៍ តម្រូវការគាំទ្រការងារតិចតួច ទំនាក់ទំនងល្អជាមួយអ្នកដទៃ និងអាចថែរក្សាសុខភាពផ្ទាល់ខ្លួន សុវត្ថិភាពពេលវេលាភាគច្រើនដោយគ្មានការគ្រប់គ្រង។
2. ភាពប្រសប់មធ្យមសំដៅលើនរណាម្នាក់ដែលឯកសារផ្សក្នុងសហគមន៍ ពេលខ្លះ តម្រូវការការគាំទ្រការងារមធ្យម គឺអាចថែរក្សាសុខភាពផ្ទាល់ខ្លួន សុវត្ថិភាពក្នុងសហគមន៍រយៈពេលខ្លី និងអាចត្រូវការការគ្រប់គ្រងខ្លះ ការបណ្តុះបណ្តាល ឬជំនួយរាងកាយជាមួយសកម្មភាពសហគមន៍។
3. ភាពប្រសប់ខ្ពស់សំដៅលើនរណាម្នាក់ដែលតម្រូវការការគាំទ្រក្នុងសហគមន៍ត្រប់ពេលដើម្បីថែរក្សាសុខភាពផ្ទាល់ខ្លួន សុវត្ថិភាព ត្រូវការការគាំទ្រការងារសំខាន់ៗ។ ត្រូវការការគ្រប់គ្រងញឹកញាប់ ការបណ្តុះបណ្តាល ឬជំនួយរាងកាយជាមួយសកម្មភាពសង្គមភាគច្រើន ឬគ្រប់ពេល។

ប្រវត្តិប្រាក់ឈ្នួលត្រូវបានកំណត់ដោយប្រាក់ដែលបុគ្គលរកបានឆ្នាំមុន។ ប្រវត្តិប្រាក់ឈ្នួលត្រូវបានបែងចែកជាប៉ីប្រភេទ ៖

1. ការងារបន្ត ៖ អតិថិជនរកប្រាក់នៅការងារមួយរយៈពេលប្រាំបួនខែឆ្នាំមុន ៖
2. ការងារថ្មី/បណ្តោះអាសន្ន ៖ អតិថិជនរកប្រាក់នៅការងារយ៉ាងតិចមួយខែឆ្នាំមុន។
3. គ្មានការងារ ៖ បុគ្គលម្នាក់មិនធ្វើការ ឬរកប្រាក់ឆ្នាំមុនទេ។

បុគ្គលធ្វើការ រកប្រាក់ និងស្វែងយល់ពីការងាររបស់ពួកគេកាន់តែយូរ ការគាំទ្រការងារដែលត្រូវការគឺកាន់តែតិច។

សម្រាប់ព័ត៌មានបន្ថែម ចូលមើល ៖
www.dshs.wa.gov/dda